# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

~~~~~~~

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:** ០៥ ស.ណន, ៧៥

## សារលិខិតជូនពរ

### សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧

**សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់**

នៅក្នុងឱកាសដ៏នក្ខត្តឫក្សថ្លៃថ្លា ប្រកបដោយសេចក្តីអភិរម្យសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៥ និងទី១៦ ខែមេសាខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃទីស្តីការគណៈរដ្ឋមន្ត្រី ខ្ញុំ និងភរិយា សូមសម្តែងនូវសេចក្តីអំណរសាទរឥតឧបមា និងសូមចូលរួមជូននូវសព្ទសាធុការពរជ័យ បវរមហាប្រសើរគ្រប់យ៉ាង ជូនចំពោះសម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ក្នុងមនោសញ្ចេតនាប្រកបដោយសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត និងសូមសម្តេចទទួលបាននូវកាយពលមាំមួន សុខភាពល្អបរិបូណ៌ បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ និងសម្រេចបាននូវលទ្ធផលផ្លែផ្កាថ្មីៗធំធេងថែមទៀត ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមថ្លៃថ្លាជាប្រវត្តិសាស្ត្រ ដឹកនាំព្រឹទ្ធសភាជាស្ថាប័ននីតិប្បញ្ញត្តិកំពូលនៃព្រះរាជាណាចក្រកម្ពុជា រួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការកែទម្រង់រដ្ឋស៊ីជម្រៅលើគ្រប់វិស័យដែលមានអភិបាលកិច្ចល្អជាស្នូលដ៏រឹងមាំ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការស្តារ និងអភិវឌ្ឍន៍មាតុភូមិអង្គរជាទីស្នេហានៃយើងទាំងអស់គ្នាលើគ្រប់វិស័យ ឱ្យមានការរីកចម្រើនជឿនលឿនឆាប់រហ័ស។

ឆ្លៀតក្នុងឱកាសដ៏នក្ខត្តឫក្សប្រសើរថ្លៃថ្លានេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ពិសេសទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ព្រះនាម **កិមិរាទេវី** សូមព្រះអង្គតាមជួយថែរក្សាការពារ និងប្រោះព្រំសព្ទសាធុការពរជ័យគ្រប់ប្រការ ចំពោះសម្តេចប្រធាន និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍តរៀងទៅ។

សូមសម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំ និងភរិយា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៧

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**ប៊ិន ឈិន**
~~~~~~~